ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្ដីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមិថុនា ឆ្នាំ២០២១

នៅក្នុងខែមិថុនា ឆ្នាំ២០២១នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

### ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

**១.១** សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន២លើក តាមប្រព័ន្ធវីដេអូ។

ខ.បដិសណ្ឋារកិច្ចឡៀវជាតិ និងអន្តរជាតិ

-បានអនុញ្ញាតឱ្យឯកឧត្តម **Martin Vavra** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឆែក ចូលជួបសម្តែងការគួរសម

-លោកស្រី **Isabel Weninger** តំណាងមូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានផ្ញើកម្រងឯកសារបោះពុម្ពថ្មីស្តីពី ឌីជីថលភាវូបនីយកម្ម ទំនាក់ទំនងអន្តរជាតិ និងចីរភាព ជូនសម្តេចប្រធានព្រឹទ្ធសភា

គ-សកម្មភាពចុះមូលដ្ឋាន

-នៅក្នុងសភាពការណ៍នៃការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយព្រឹត្តការណ៍សហគមន៍ ២០ កុម្ភៈ សម្តេចប្រធានបានអញ្ជើញមកប្រចាំការដើម្បីដឹកនាំការងារជំនាញរៀងរាល់ថ្ងៃ និងដឹកនាំចាត់ចែងចូលរួមចំណែកដោះស្រាយជំនួយឧបត្ថម្ភបន្ទាន់ រួមមាន៖ អង្ករ ត្រីខកំប៉ុង ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកផ្លែឈើ ឱសថ និងសម្ភារប្រើប្រាស់មួយចំនួនជូនមន្ត្រី កងកម្លាំង និងប្រជាពលរដ្ឋក្រីក្រ ដែលរងផលប៉ះពាល់ពីការបិទខ្ទប់នៅក្នុងមូលដ្ឋានរាជធានីភ្នំពេញជាបន្តបន្ទាប់។ ព្រមជាមួយនេះ

សម្តេចប្រធានក៏បានណែនាំ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា ជាទីប្រឹក្សាថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឱ្យជួយដោះស្រាយនូវអំណោយចាំបាច់នានាទៅតាមលទ្ធភាព ដើម្បីចែកជូនប្រជាពលរដ្ឋងាយរងគ្រោះ និងប្រជាពលរដ្ឋក្រីក្រដែលកំពុងរស់នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងខេត្តមួយចំនួនទៀតផងដែរ

-បានអញ្ជើញពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ជាចំណងដៃរបស់សម្តេច និងរាជរដ្ឋាភិបាល រួមមាន៖ សាលាឆទាន ស្ពាន ទំនប់បង្ហៀរ ផ្លូវបេតុង ស្ថិតនៅក្នុងឃុំកោះមិត្ត ស្រុកកំពង់សៀម និងឃុំកោះសូទិន ស្រុកកោះសូទិន។ បន្ទាប់ពីត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធរួចមក សម្តេចប្រធានព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខ លោកយាយ លោកតា និងបងប្អូនប្រជាពលរដ្ឋ នៅស្រុកកំណើតរបស់សម្តេច ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

- បានចាត់តាំងឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាជាតំណាង ដើម្បីនាំយកនូវគ្រឿងឧបភោគ បរិភោគ និងសម្ភារប្រើប្រាស់មួយចំនួនចុះសួរសុខទុក្ខ និងជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋក្រីក្រ ជួបការខ្វះខាតខ្លាំង នៅក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

**ឃ.សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញថ្វាយបង្គំ សាកសួរព្រះរាជសុខភាពសម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** សម្តេចព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តបុទមវតីរាជវរារាម ព្រមទាំងប្រគេនបច្ច័យចំនួន១០.០០០ដុល្លារអាមេរិក ដើម្បីព្យាបាលព្រះរាជសុខភាព

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធ និងផ្តល់ភ្លើងបូជាសពឯកឧត្តម **ត្រាំ អ៊ីវតឹក** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស នៅវត្តបទុមវត្តីរាជវរារាម រាជធានីភ្នំពេញ

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធ និងផ្តល់ភ្លើងបូជាសពឯកឧត្តម **លុយ ឡាំ** ទីប្រឹក្សាសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ស្ថិតនៅក្នុងភូមិសំណាង់ សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **នង តាំងអ៊ីម** មាតាបង្កើតរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួល

បន្ទុកជាអគ្គនាយកដ្ឋានពន្ធដារ និងសពលោកជំទាវ **ហាម អ៊ីម** ដែលត្រូវជាភរិយាឯកឧត្តម **បាន់ ប៉េង** នៅគេហដ្ឋាននៃសព រាជធានីភ្នំពេញ និងខេត្តកំពង់ចាម។

ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៨ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ គា អនុប្រធានទី១ ព្រឹទ្ធសភា**

ក.សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន២លើក តាមប្រព័ន្ធវីដេអូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

ខ-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញចុះពិនិត្យសមិទ្ធផលនានា នៅវត្តទេពនិម្មិត និងនាំយកថវិកាមួយចំនួនប្រគេនគណៈកម្មការវត្ត ដើម្បីទូទាត់ការចំណាយផ្សេងៗ នៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

ក.សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន២លើក តាមប្រព័ន្ធវីដេអូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារផ្ទៃក្នុងព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

ខ-សកម្មភាពចុះមូលដ្ឋាន

-បានចាត់តាំងឯកឧត្តម **ស្រី បេន** សមាជិកព្រឹទ្ធសភានាំយកអំណោយទៅប្រគល់ជូនស្នងការនគរបាលខេត្តតាកែវ ដើម្បីប្រើប្រាស់ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។

គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៧ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា តាមប្រព័ន្ធវីដេអូ ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន **ស្មេថេក ខូ អិលធីឌី** សម្រាប់គម្រោងអភិវឌ្ឍន៍អគ្គិសនីតង់ស្យុង៥០០ គីឡូវ៉ុល ពីខេត្តបាត់ដំបងទៅកាន់ព្រំដែនកម្ពុជា-ថៃ

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន **ស្មេថេក ខូ អិលធីឌី** សម្រាប់គម្រោងអភិវឌ្ឍន៍អគ្គិសនីតង់ស្យុង៥០០ គីឡូវ៉ុល ពីរាជធានីភ្នំពេញទៅកាន់ព្រំដែនកម្ពុជា-ឡាវ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន **ឆាយណា ណេសិនណល ហៅវី ម៉ាស៊ីនណឺរី ឌបភើវេសិន** សម្រាប់គម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងតាតៃលើអនុភាព១៥០ មេហ្គាវ៉ាត់ ខេត្តកោះកុង

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន **អគ្គិសនីវៀតណាម** នៃសាធារណរដ្ឋសង្គមនិយមវៀតណាម សម្រាប់ធានាលើការទិញថាមពលអគ្គិសនីពីប្រទេសវៀតណាម

៥-ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ នីតិកាលទី៤។

## ៣.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៣.១ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន១ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន៦ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៦ករណី តម្កល់ទុកមិនចាត់ការចំនួន១ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៦ករណី

-បានអញ្ជើញចូលរួមប្រជុំការងារជាមួយលោកអភិបាល អភិបាលស្រុករង លោកមេឃុំ និងមន្ត្រីសាលាស្រុក ស្តីពីការងារពង្រឹងសន្តិសុខ សុវត្ថិភាពភូមិ-ឃុំ ការងារផ្តល់

សេវាសារធារណៈ ការងារជំរុញធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ដែលទើបគ្រប់អាយុ១៨ឆ្នាំ និងការប្រុងប្រយត្ន័ការពារកុំឱ្យឆ្លងជំងឺកូវីដ-១៩ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

-បានអញ្ជើញចុះទៅឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដើម្បីស្តាប់របាយការណ៍ប្រមូលព័ត៌មានពីមេភូមិ ក្រុមប្រឹក្សាឃុំ ក្នុងបរិបទសម័យកូវីដ-១៩ ព្រមទាំងបានចូលរួមដោះស្រាយបញ្ហាផ្សេងៗ

-បានអញ្ជើញចូលរួមពិធីប្រកាសតែងតាំងថ្នាក់ដឹកនាំក្រុមប្រឹក្សាយោបល់ និងថ្នាក់ដឹកនាំ សមាជិក-សមាជិកាសមាគមរាជសីហ៍សាខាប្រទេសជប៉ុន នៅសាលាភាសាជប៉ុនមិរ៉ៃ រាជធានីភ្នំពេញ តាមប្រព័ន្ធវីដេអូ

-បានអញ្ជើញដឹកនាំអង្គប្រជុំ ដើម្បីដោះស្រាយបញ្ហាកង្វល់របស់កសិករខ្នាតតូច មធ្យម និងខ្នាតធំ ដែលជួបការលំបាកកន្លងមក នៅសភាពាណិជ្ជកម្មកម្ពុជា តាមប្រព័ន្ធវីដេអូ

-បានអញ្ជើញចុះពិនិត្យលទ្ធផលនៃការបោះបង្គោលព្រំដីអភិរក្ស និងអភិវឌ្ឍន៍តំបន់ព្រៃលិចទឹក និងពិនិត្យលទ្ធផលនៃការកសាងប្រព័ន្ធធារាសាស្ត្រដែលជាអំណោយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅតំបន់បឹងការដេ ភូមិបារាយណ៍ ឃុំឈូក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

-បានអញ្ជើញជាអធិបតីក្នុងពិធីដាំកូនឈើចំនួន១៥០ដើម ក្នុងនោះមានកូនគ្រញូងចំនួន៦០ដើម កូនធ្នង់ចំនួន៦០ដើម និងកូនគគីចំនួន៣០ដើម ស្ថិតនៅទីធ្លាវត្តក្តីចារ្តិ ភូមិទៀមចាស់ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

-បានអញ្ជើញចូលរួមពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ ជូនដល់យុវជនស្រុកអន្លង់វែងចំនួន៣០០នាក់ នៅខេត្តឧត្តរមានជ័យ

-បានអញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការ មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារក្នុងបរិបទកូវីដ-១៩ បញ្ហាប្រឈម និងទិសដៅអនុវត្តបន្ត

- សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ព្រមទាំងនាំយកគ្រឿងឧបភោគបរិភោគ ម៉ាស អាកុល ជែល និងថវិកាមួយចំនួនចែកជូនប្រជាពរដ្ឋដែលកំពុងជួបការលំបាក ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបានបំពេញភារកិច្ចផ្សេងៗទៀត នៅមូលដ្ឋានរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន១៥០លើក។

## ៣.២ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-គណៈប្រតិភូសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើប្រាស់ភាសាបារាំង(APF) តាមប្រព័ន្ធវីដេអូ

-គណៈប្រតិភូសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយសហភាពអន្តរសភា (IPU) បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃមហាសន្និបាតសហភាពអន្តរសភាលើកទី១៤២ តាមប្រព័ន្ធវីដេអូ

-បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមរៀបចំសន្និសីទលើកទី៨ នៃគណៈកម្មការកិច្ចការបរទេសនៃសភាកម្ពុជា-ឡាវ និងវៀតណាម(CLV)

-បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមរៀបចំកិច្ចប្រជុំភាពជាដៃគូសភាអាស៊ីអឺរ៉ុបលើកទី១១ (ASEP11) តាមប្រព័ន្ធវីដេអូ

-បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមចូលរួមកិច្ចប្រជុំជាន់ខ្ពស់ស្តីពី មេរោគអេដស៍/ជំងឺអេដស៍របស់អង្គការសហប្រជាជាតិ តាមប្រព័ន្ធវីដេអូ

-លោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោក **Serge Bellini** នាយកសម្ព័ន្ធភាពបារាំងប្រចាំខេត្តសៀមរាប និងជាកុងស៊ុលកិត្តិយសសហគមន៍បារាំងប្រចាំខេត្តសៀមរាប ចូលជួបសម្តែងការគួរសម និងជម្រាបលា

-លោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា និងជាអនុប្រធានក្រុមមិត្តភាពទ្វេភាគីកម្ពុជា-បារាំង បានអញ្ជើញទទួលគ្រឿងឥស្សរិយយស La médaille de Chevalier dans l'ordre national du mérite នៃរដ្ឋាភិបាលសាធារណរដ្ឋបារាំង។

**ថ្ងៃ**សុក្រ ១៥រោច **ខែ**បឋមាសាឍ **ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥**

**រាជធានីភ្នំពេញ, ថ្ងៃទី**០៩ **ខែកក្កដា ឆ្នាំ២០២១**

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

*កិត្តិសង្គហបណ្ឌិត* **ទេព ងន**

*ចម្លងជូន*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*